# របាយការណ៍ប្រចាំខែកក្កដា ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែកក្កដា ឆ្នាំ២០១៦ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. **<u>ស្ថានភាពមន្ត្រីរាជការ</u>÷**

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ មានមន្ត្រីក្របខណ្ឌ និងកិច្ចសន្យាសរុបចំនួន ៣១ នាក់ ស្ត្រី ០៤ នាក់ ដឹកនាំដោយប្រធានមន្ទីរ ០១រូប និងអនុប្រធានមន្ទីរ ០២រូប ។

2. **<u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>÷**

- ចូលរួមវេទិកាសាធារណៈចំនួន ០៤ដង
- ចូលរួមពិធីប្រលែងកូនត្រី នៅឃុំខ្សាច់អណ្តែត ស្រុកឆ្លូង ថ្ងៃទី០២ កក្កដា ២០១៦
- ចូលរួមប្រជុំប្រចាំខែមិថុនា ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៦ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមប្រជុំបណ្តាញយេនឌ័រថ្នាក់ខេត្តប្រចាំឆមាសទី១ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី
- ចូលរួមរុក្ខទិវាថ្នាក់ខេត្តនៅសកលវិទ្យាល័យក្រចេះ ថ្ងៃទី០៧ កក្កដា ២០១៦
- ចូលរួមប្រជុំបូកសរុបប្រចាំឆមាសស្តីពីការប៉ាន់ប្រម៉ាណផលប៉ះពាល់គ្រោះមហន្តរាយ ថ្ងៃទី០៦ កក្កដា ២០១៦ នៅសាលប្រជុំសាលាខេត្តក្រចេះ
- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយថ្នាក់ខេត្ត ស្តីពីTrad SWAp.ELF-Trer2 CEDEP II នៅកំពង់ចាម ថ្ងៃទី១៣ កក្កដា
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីពង្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មរយៈពេល៥ឆ្នាំ ២០១៦-២០២០ នៅសណ្ឋាគារ ហ៊ារ បុន្នី ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦
- ចូលរួមប្រជុំការងារគ្រោះមហន្តរាយ ថ្ងៃទី១២ កក្កដា ២០១៦ សាលប្រជុំសាលាខេត្តក្រចេះ
- ចូលរួមប្រជុំសរុបលទ្ធផលការងារគ្រប់វិស័យប្រចាំឆមាសទី១ ឆ្នាំ២០១៦ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ សាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំ ពិភាក្សាកម្រិតបច្ចេកទេសលើគម្រោងចំនូលចំណាយថវិកាឆ្នាំ២០១៧ ថ្ងៃទី១៩ កក្កដា ២០១៦ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមពិធីប្រកាសចូលកាន់តំណែងប្រធាន អនុប្រធានលេខាធិកាដ្ឋានរដ្ឋបាលសាលាដំបូងខេត្តក្រចេះ ព្រមទាំងប្រគល់ត្រាជាផ្លូវការ ថ្ងៃទី២៨ កក្កដា ២០១៦ សាលមហោស្រពខេត្តក្រចេះ
- ចូលរួមប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត លើគម្រោងលើកកម្ពស់សន្តិសុខស្បៀងតាមសហគមន៍ និងទីប្រជុំជនរណប ថ្ងៃទី១៩ កក្កដា ២០១៦ នៅមន្ទីរកសិកម្មខេត្តក្រចេះ

- ចូលរួមកសាងផែនការវិនិយោគថ្នាក់ឃុំ ថ្ងៃទី២០ កក្កដា ២០១៦ នៅសាលាឃុំបុសលាវ
- ចូលរួមប្រជុំក្រុមប្រឹក្សាលើកទី២៦ អាណត្តិទី២ ឆ្នាំទី៣ របស់ក្រុមប្រឹក្សាខេត្តក្រចេះ ថ្ងៃទី២១ កក្កដា ២០១៦ នៅសាលប្រជុំក្រុមប្រឹក្សាខេត្តក្រចេះ
- ចូលរួមផ្សព្វផ្សាយគម្រោងពង្រឹកអំណាចសហគមន៍ក្នុងការបន្សាំនឹងបម្រែបម្រួលអាកាសធាតុ ថ្ងៃទី២៩ កក្កដា ឆ្នាំ២០១៦ នៅការិយាល័យអង្គការ KWWA ទល់មុខវិទ្យាល័យក្រចេះក្រុង ។

3. <u>**សកម្មភាពតាមការិយាល័យ**</u>÷

3.1. **ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ**

ក. ផ្នែកការងារលិខិតចូល ÷ សរុបចំនួន ៤៦ លេខ ក្នុងនោះមាន :

- លិខិតចូលពីអង្គភាពនានាជុំវិញខេត្ត ចំនួន ៣៩ លេខ
- លិខិតក្រសួងសាមី និងអង្គភាពក្រោមឱវាទមន្ទីរ ចំនួន ០៧ លេខ

ខ. ផ្នែកការងារលិខិតចេញ ÷ សរុបចំនួន ៦០ លេខ ក្នុងនោះមាន :

- លិខិតចេញទៅបណ្តាអង្គភាពនានាក្រោមន្ទីរ ចំនួន ១៤ លេខ
- លិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការ ចំនួន ៣៣ លេខ
- លិខិតចេញទូទៅ លិខិតអញ្ជើញ និងសេចក្តីជូនដំណឹង ចំនួន ០៤ លេខ
- លិខិតចេញទៅបណ្តាអង្គភាពនានា និងក្រសួងសាមី ចំនួន ០៩ លេខ

គ. ផ្នែកបញ្ជីវត្តមាន÷ ពិនិត្យការចុះបញ្ជីវត្តមានប្រចាំថ្ងៃ ។

3.2. <u>**ការិយាល័យផ្លូវជនបទ**</u>÷

<u>**សកម្មភាពការងារ**</u>

- ចុះធ្វើបច្ចុប្បន្នភាពផ្លូវ ប្រភេទទី៣ និងប្រភេទទី៤ បានចំនួន ៣ខ្សែ ប្រវែង ២២ ០០០ ម ស្ថិតនៅឃុំសំបុក ឃុំចង្រ្កង់ ឃុំថ្មគ្រែ ឃុំគោលាប់ ឃុំកន្ទួត និងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ។
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវ ប្រភេទទី៤ បានចំនួន ៦ ខ្សែ ប្រវែង ៨ ៨៧១ ម ស្ថិតនៅឃុំព្រែកប្រសព្វ និងឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ
- ចុះស្រង់ទិន្នន័យផ្លូវ ប្រភេទទី៤ បានចំនួន ១ ខ្សែ ប្រវែង ៧ ៣០០ ម ស្ថិតនៅឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ។
- ចុះពិនិត្យការងារជួសជុលថែទាំជាលក្ខណៈខួប ចំនួន ០១ ខ្សែ ប្រវែង ១០ ០០០ ម ស្ថិតនៅភូមិព្រែកចំឡាក់ (ឧបសម្ពន្ធ័ភូមិខ្សាច់វែង)ទៅភូមិដារជ្រៃ ឃុំកញ្ជរ ស្រុកឆ្លូង បានចំនួន ០៣ លើក
- ចុះពិនិត្យការងារជួសជុលថែទាំជាលក្ខណៈប្រចាំ ចំនួន ០៣ ខ្សែ ប្រវែង ៥១ ០០០ ម ស្ថិតនៅឃុំកំពង់ដំរី ស្រុកឆ្លូង និងឃុំអូរគ្រៀង ស្រុកសំបូរ បានចំនួន ០២ លើក
- ពិនិត្យ និងបញ្ជាក់បច្ចេកទេសលើគម្រោង មូលនិធិឃុំ/សង្កាត់ ស្រុក ក្រុង របស់រដ្ឋបាលខេត្តក្រចេះ បានចំនួន ០៣ គម្រោង ។

លទ្ធផលការងារ

- ការងារជួសជុលថែទាំជាលក្ខណៈខួប ចំនួន ០១ ខ្សែ ប្រវែង ១០ ០០០ ម ស្ថិតនៅភូមិព្រែកចំឡាក់ (ឧបសម្ព័ន្ធ) ភូមិខ្សាច់វែង ទៅភូមិដារជ្រៃឃុំកញ្ចរ ស្រុកឆ្លូង លទ្ធផលសម្រេចបាន ៤៥% (ថវិកាតាមរយៈក្រសួង)
- ចុះជួសជុលផ្លូវថែទាំជាលក្ខណៈប្រចាំ ចំនួន ០៣ខ្សែ ប្រវែង ៥១ ០០០ ម ស្ថិតនៅឃុំកំពង់ដំរី ស្រុកឆ្លូង និងឃុំអូរគ្រៀង ស្រុកសំបូរ លទ្ធផលសម្រេចបាន ៤០% (ថវិកាតាមរយៈក្រសួង)។

3.3. **ការិយាល័យផ្គត់ផ្គង់ទឹកជនបទ÷**

- ចុះជួសជុលអណ្តូងស្នប់ខូចបានចំនួន ៦៩អណ្តូងក្នុងនោះថវិកាខេត្ត៥៦អណ្តូង ថវិកាក្រសួង ១២អណ្តូង
    - ស្រុកស្នួល បានចំនួន ១៧អណ្តូង ថវិកាខេត្ត ១១អណ្តូង ថវិកាក្រសួង ចំនួន ០៦អណ្តូង
    - ស្រុកសំបូរបានចំនួន ១១អណ្តូង ថវិកាខេត្ត ០៤អណ្តូង ថវិកាក្រសួង ចំនួន ០៦អណ្តូង
    - ស្រុកចិត្របុរី បានចំនួន ៤២អណ្តូង ថវិកាខេត្ត
- ចុះជ្រើសរើសទីតាំង អាងត្រង់ទឹកភ្លៀង នៅស្រុកចិត្របុរីចំនួន ០៧កន្លែង ។

3.4. **ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ÷** (គ្មានសកម្មភាព)

3.5. **ការិយាល័យអភិវឌ្ឍន៍សហគមន៍÷**

ចុះត្រួតពិនិត្យតាមដានសកម្មភាព និងធ្វើបច្ចុប្បន្នភាពសមាសភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ចំនួន ០៨ ភូមិ ក្នុងឃុំបុសលាវ ។

3.6. **ការិយាល័យជនជាតិដើមភាគតិច÷**

ចូលរួមប្រជុំពេញអង្គ របស់សមាគមន៍ជណជាតិដើមភាគតិច និងពិនិត្យលើ ឯកសារសេចក្តីសម្រេចគណៈកម្មាធិការ និងលក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិច នៅភូមិក្បៀ និងភូមិស្រែជិះ ឃុំស្រែជិះ ស្រុកសំបូរ ខេត្តក្រចេះ ដែលមានអ្នកចូលរួមសរុប ១២៨ នាក់ ស្ត្រី ៥២ នាក់ ។

3.7. **ការិយាល័យថែទាំសុខភាពជនបទ÷**

- ចុះផ្សព្វផ្សាយសកម្មភាព ស្តីពីការលើកកម្ពស់អនាម័យតាមសហគមន៍ និងពង្រឹងបណ្តាញជនបង្គោលស្ម័គ្រចិត្តភូមិនៅ ឃុំកោះខ្នែរ និងឃុំវឌ្ឍនៈ ដែលមានអ្នកចូលរួមសរុប ចំនួន ៦៩ នាក់/ ស្ត្រី ២៣ នាក់
- បំផុសអោយប្រជាពលរដ្ឋចូលរួមស្ម័គ្រចិត្តសាសង់បង្គន់ខ្លួនឯងក្នុងឃុំចំនួន ៤ ដូចខាងក្រោម÷
    - ឃុំព្រែកសាម៉ាន់ ចំនួន ៣៨ គ្រួសារ
    - ឃុំកញ្ចរ ចំនួន ២២ គ្រួសារ
    - ឃុំដារ ចំនួន ២៣ គ្រួសារ
    - ឃុំឆ្លូង ចំនួន ៥២ គ្រួសារ ។

3.8. <u>ការងារបណ្តុះបណ្តាលមន្ត្រីរាជការ÷</u>

- លោក ធុន សារី អនុប្រធានមន្ទីរ លោក តុញ យ៉ាវ អនុប្រធានការិយាល័យផ្លូវជនបទ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី របៀបប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យផ្លូវជនបទ កាលពីថ្ងៃទី ២២ - ២៣ ខែមិថុនា ឆ្នាំ ២០១៦ នៅសាលប្រជុំក្រសួងអភិវឌ្ឍន៍ជនបទជាន់ទី៣ ក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោកស្រី ធុន បូនិត មន្ត្រីការិយាល័យគណនេយ្យ -ហិរញ្ញវត្ថុ បានចូលរួមសិក្ខាសាលាស្តីពីការយល់ដឹងពីការអនុវត្តន៍អនុសញ្ញា ស្តីពីសិទ្ធិកុមារ កាលពីថ្ងៃទី ២២ - ២៤ ខែមិថុនា ឆ្នាំ ២០១៦ សាលប្រជុំមន្ទីរសង្គមកិច្ចខេត្តក្រចេះ រៀបចំដោយអង្គការ CEDAW ។
- លោក ឃាន់ ធន មន្ត្រីការិយាល័យអភិវឌ្ឍន៍សហគមន៍ បានចូលរួមសិក្ខាសាលាឆ្លុះបញ្ចាំងលទ្ធផលសម្រេចបានរបស់គម្រោងភាពធន់ទ្រាំ ទៅនឹងការប្រែប្រួលអាកាសធាតុ និងសន្តិសុខស្បៀង នៅសណ្ឋាគារ ហ៊ ប៊ុន្នី កាលពីថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០១៦ ។
- លោក អ៊ុត អុល ប្រធានការិយាល័យផែនការ និងស្ថិតិ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការកសាងកម្មវិធីវិនិយោគ ០៣ ឆ្នាំរំកិល កាលពីថ្ងៃទី ០៥-០៦ ខែកក្កដា ឆ្នាំ ២០១៦ នៅសាលប្រជុំសាលា ស្រុកព្រែកប្រសព្វ ។
- លោក ហៃ មីត ប្រធានការិយាល័យសុខភាពបឋមជនបទ លោក ជុន ដន ប្រធានការិយាល័យផ្គត់ផ្គង់ទឹកជនបទ លោក ឈាង ស៊ីថា ប្រធានការិយាល័យបណ្តុះបណ្តាល លោក ឃាន់ ធន លោក ឃិន រ៉េមី មន្ត្រីការិយាល័យផ្គត់ផ្គង់ទឹកជនបទ បានចូលរួមសិក្ខាសាលា ផ្លាស់ប្តូរបទពិសោធន៍ការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ កាលពីថ្ងៃទី ១១-១៣ ខែកក្កដា ឆ្នាំ ២០១៦ នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ រៀបចំដោយអង្គការ Unicef ។
- លោក លឹម ជាវហាវ ប្រធានមន្ទីរ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី÷ ពង្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មរយៈពេល៥ឆ្នាំ (២០១៦-២០២០)កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០១៦ នៅសណ្ឋាគារ ហ៊ ប៊ុន្នី រៀបចំដោយមន្ទីរកសិកម្មខេត្តក្រចេះ ។
- លោក ម៉ៅ សុខជា អនុប្រធានមន្ទីរ លោក ជុន ដន លោក ឈាង ស៊ីថា លោក ឃិន រ៉េមី លោក ឃាន់ ធន បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការបន្សុទ្ធ និងស្តុកទឹកទុកអោយមានសុវត្ថិភាពតាមគ្រួសារ កាលពីថ្ងៃទី ១៩-២២ ខែកក្កដា ឆ្នាំ ២០១៦ នៅមន្ទីរហិរញ្ញវត្ថុខេត្តស្ទឹងត្រែង រៀបចំដោយអង្គការ Unicef ។

4. <u>ទិសដៅបន្ត÷</u>

- ចុះជួសជុលថែទាំជាលក្ខណៈខួបចំនួន ០១ ខ្សែ ប្រវែង ១០,០០០ ម ស្ថិតនៅភូមិព្រែកចំឡាក់ (ឧបសម្ព័ន្ធ ភូមិខ្សាច់វែង) ទៅភូមិដារជ្រៃ ឃុំកញ្ជរ ស្រុកឆ្លូង ខេត្តក្រចេះ

- ចុះជួសជុលផ្លូវថែទាំជាលក្ខណៈប្រចាំ ចំនួន ០៣ ខ្សែ ប្រវែង ៥១ ០០០ ម ស្ថិតនៅ ឃុំកំពង់ដំរី ស្រុកឆ្លូង និងឃុំអូរគ្រៀង ស្រុកសំបូរ
- ចុះស្រង់ទិន្នន័យផ្លូវ និងធ្វើបច្ចុប្បន្នភាពផ្លូវ នៅស្រុកចិត្របុរី ស្រុកសំបូរ និងស្រុកស្នួល
- ជួសជួលអណ្តូងនៅស្រុកចិត្របុរី និងស្រុកស្នួល
- ចុះទៅតាមដានសកម្មភាព និងធ្វើបច្ចុប្បន្នភាព គ.អ.ភ ឃុំកញ្ជរ ស្រុកឆ្លូង
- បន្តការបំផុសអោយប្រជាពលរដ្ឋចូលរួមសាងសង់បង្គន់ដោយខ្លួនឯងក្នុងស្រុកឆ្លូង ស្រុកចិត្របុរី ស្រុកព្រែកប្រសព្វ ស្រុកសំបូរ និងក្រុងក្រចេះ
- ផ្តល់សម្ភារៈសាងសង់បង្គន់នៅឃុំកោះខ្ញែរ និងឃុំវឌ្ឍនៈ
- ចុះទៅវាស់វែងចុះបញ្ជីដីធ្លីក្នុងឃុំរលួស និងឃុំស្រែជិះ ស្រុកសំបូរ ។

**ប្រធានមន្ទីរ**